# ២ - សតិចេតសិក (Mindfulness)

មើលវីដេអូ ភាគទី ១៤

សរណំ = សតិ អសម្មោសោ សេចក្តីរលឹក ឈ្មោះថា សតិ បានដល់សេចក្តីមិនវង្វេងភ្លេច ។

ម្យ៉ាងទៀត សរន្តិ ឯតាយ សយំ វា សរតិ សរណមត្តមេវ វា ឯសាតិ = សតិ បុគ្គលរមែងរលឹកបាន ដោយធម្មជាតិនោះ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា សតិ ឬធម្មជាតិនោះ រមែងរលឹកបានខ្លួនឯង ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា សតិ ឬថា ធម្មជាតិនោះ ត្រឹមតែជាការរលឹកប៉ុណ្ណោះ ព្រោះហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា សតិ គឺ សេចក្តីរលឹកបាន។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

សតិ រលឹកដឹងអំពីពោធិបក្ខិយធម៌ ៣៧ ប្រការតាមសេចក្ដីពិត

សតិ មានការពិចារណាការសម្រេចនៃធម៌ដែលជាប្រយោជន៍ និង មិនមែនជាប្រយោជន៍

សតិ ដឹងថា ធម៌មានកាយទុច្ចរិតជាដើម មិនជាប្រយោជន៍ រមែងកាត់បន្ថយនូវធម៌ដែលមិនជាប្រយោជន៍នោះ

សតិ ដឹងថា ធម៌មានកាយសុចរិតជាដើម ជាប្រយោជន៍រមែងចម្រើននូវធម៌ជាប្រយោជន៍នោះ

**សតិ** ប្រៀបដូចនាយបរិនាយកកែវរបស់ស្តេចចក្រពត្តិ ដឹងនូវវត្ថុដែលមិនជាប្រយោជន៍ និងវត្ថុដែលជាប្រយោជន៍ រមែងនាំយកវត្ថុដែលមិនជាប្រយោជន៍ចេញទៅ និងបង្អោននូវវត្ថុដែល ជាប្រយោជន៍ចូលមក។

**សតិ** រមែងរក្សាចិត្តចេញពីអកុសលធម៌ និងញ៉ាំងចិត្តឲ្យប្រកបដោយកុសលធម៌ ប្រៀបដូចមហាអាមាត្យអ្នកធ្វើកិច្ចរបស់ព្រះរាជាឲ្យសម្រេច សមដូចព្រះពុទ្ធវចនៈថា **សតឹ ខ្វាហំ ភិក្ខវេ សព្វត្ថិកំ វទាមិ** ម្នាលភិក្ខុទាំងឡាយ តថាគតពោល នូវសតិថាមានឧបការច្រើនក្នុងទីទាំងពួង។

**សតិ** គឺជាឈ្មោះនៃ អប្បមាទធម៌។

# លក្ខណាទិចតុក្កៈរបស់សតិ

១ - អភិលាបនលក្ខណា មានការរលឹកបាន មិនរវើរវាយ ជាលក្ខណៈ

២ - អសម្មោសរសា មានការមិនវង្វេងភ្លេច ជាកិច្ច

៣ - វិសយាភិមុខភាវបច្ចុប្បដ្ឋានា មានការប្រាថ្នាចំពោះអារម្មណ៍ (ឬមានការរក្សាទុកនូវអារម្មណ៍មិនឲ្យចេញអំពីចិត្ត) ជាអាការប្រាកដ

៤ - ថិរសញ្ញាបទដ្ឋានា មានការចាំប្រាកដ ជាហេតុជិត

កាយាទិសតិបទដ្ឋានា វា ឬថា មានសតិប្បដ្ឋាន ដូចជាកាយជាដើម ជាហេតុជិត។

# ៣ - ហិរិចេតសិក [ (Moral) Shame ]

ហិរិយតិ កាយទុច្ចរិតាទីហិ ជិគុច្ឆតីតិ = ហិរិ ធម្មជាតិ ដែលឈ្មោះថា ហិរិ ព្រោះអត្ថថា ខ្មាស គឺ រង្កៀសចំពោះទុច្ចរិត មានកាយទុច្ចរិតជាដើម។ ហិរិ ការខ្មាស ឬខ្ពើមអំពើបាបរបស់ខ្លួនឯង ប្រៀបដូចបុគ្គលមិនចង់ចាប់កាន់ដុំដែក (មិនក្តៅ) ដែលប្រឡាក់ដោយមន្ទិលមានលាមកជាដើម។

# លក្ខណាទិចតុក្កៈរបស់ហិរិ

| | |
|---|---|
| ១ - បាបតោ ជិគុច្ឆនលក្ខណា | មានការរង្កៀសចំពោះបាប ជាលក្ខណៈ |
| ២ - បាបានំ អករណរសា | មានការមិនធ្វើបាប ជាកិច្ច |
| ៣ - បាបតោ សង្កោចនបច្ចុប្បដ្ឋានា | មានការថយចាកពីបាប ជាអាការប្រាកដ |
| ៤ - អត្តគារវបទដ្ឋានា | មានការគោរពខ្លួនឯង ជាហេតុជិត។ |

## ៤ - ឱត្តប្បចេតសិក [ (Moral) Dread ]

តេហិយេវ ឱត្តប្បតីតិ = ឱត្តប្បំ ធម្មជាតិណា រមែងក្រែងខ្លាចចំពោះទុច្ចរិតទាំងនោះឯង ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា ឱត្តប្បៈ។

ឱត្តប្បៈ ការខ្លាចចំពោះបាប ប្រៀបដូចបុគ្គលមិនហ៊ានចាប់ កាន់ដុំដែកដែលគេដុតឲ្យក្ដៅ។

# លក្ខណាទិចតុក្កៈរបស់ឱត្តប្បៈ

| | |
|---|---|
| ១ - ឧត្តាសលក្ខណំ | មានការតក់ស្លុតចំពោះបាប ជាលក្ខណៈ |
| ២ - បាបានំ អករណរសំ | មានការមិនធ្វើបាប ជាកិច្ច |
| ៣ - បាបតោ សង្កោចនបច្ចុប្បដ្ឋានំ | មានការថយចាកបាប ជាអាការប្រាកដ |
| ៤ - បរគារវបទដ្ឋានំ | មានការគោរពអ្នកដទៃ ជាហេតុជិត។ |